មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI00149

# សម្ភាសន៍ជាមួយឈ្មោះ ចាន់ ឌៀល ភេទស្រី អាយុ៥០ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័ត

## រស់នៅភូមិដើមវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## សម្ភាសន៍ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

## ០០:៤៧:៥៣

## ២៤ទំព័រ

វណ្ណៈ ថ្ងៃហ្នឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ហើយខ្ញុំឈ្មោះសុខ វណ្ណៈ មកពីមជ្ឈមណ្ឌលឯកសាកម្ពុជា ហើយខ្ញុំមកដល់ក្នុងភូមិឃុំរបស់មីងព្រោះចង់ដឹងពីរឿងរ៉ាវប្រវត្តិសាស្ត្រ ទាក់ទងនឹងសម័យខ្មែរក្រហម កាលពីឆ្នាំ១៩៧៥ពេលដែលខ្មែរក្រហមចូលកាន់កាប់ទូទាំងប្រទេសរហូតដល់ឆ្នាំ៧៩ ចង់ដឹងថាប្រជាជននៅខាងតំបន់៥នេះ គេហៅថាពីសម័យខ្មែរក្រហម ខេត្តបាត់ដំបង ។ ឥឡូវគេហៅបន្ទាយមានជ័យ កាលហ្នឹងតើជួបការលំបាកយ៉ាងម៉េចខ្លះ ទាំងមូលដ្ឋានចាស់ ហើយនឹងមូលដ្ឋានថ្មីអ្នកថ្មីដែលមកពីភ្នំពេញហ្នឹង តើអ្នកទាំងអស់ហ្នឹងជួបហេតុការអីខ្លះ បើមីងបានដឹងប៉ុណ្ណា បើសិនជាខ្ញុំសួរទៅមីងដឹងក៏ឆ្លើយទៅ បើមិនកន្លែងណាមិនដឹងក៏មិនអីដែរ តែបទសម្ភាសន៍ខ្ញុំជាមួយមីងហ្នឹង តើមីងអនុញ្ញាតឲ្យពួកខ្ញុំហ្នឹងយកទៅសរសេរចងក្រងជាប្រវត្តិសាស្ត្របានទេមីង?

ឌៀៈ ស្រេចតែក្មួយទេ ខ្ញុំមិនថាអីទេ ។

វណ្ណៈ មីងមិនថាអីទេ?

ឌៀៈ ចា៎!

វណ្ណៈ យើងចូលរួមរកយុត្តិធម៌ ស្វែងរកការពិតជូនបងប្អូនដែលស្លាប់ទៅ ហើយនឹងយើងចង់ឲ្យមានជាប្រវត្តិសាស្ត្រដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮ អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង តើមីងឈ្មោះអីដែរ?

ឌៀៈ ខ្ញុំឈ្មោះ ចាន់ ឌៀ ។

វណ្ណៈ អាយុប៉ុន្មានហើយមីង?

ឌៀៈ អាយុ៥០ ។

វណ្ណៈ ប្តីមីងឈ្មោះអី?

ឌៀ៖ ឈ្មោះគង់ សារឿន ។

វណ្ណៈ គាត់ប្រហែលអាយុប៉ុន្មានដែរ?

ឌៀ៖ គាត់អាយុ៥៥ហើយ ។

វណ្ណៈ មីងមានកូនប៉ុន្មាននាក់?

ឌៀ៖ កូន៤នាក់ ។

វណ្ណៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឌៀ៖ ស្រី២នាក់ ហើយប្រុស២នាក់ ។

វណ្ណៈ ឪពុកមីងឈ្មោះអី?

ឌៀ៖ ឈ្មោះក្រង ឌៀន ។

វណ្ណៈ គាត់អាយុ៨០ជាងហើយមែនទេ?

ឌៀ៖ ៨៧-៨៨ហើយ ។

វណ្ណៈ ចុះម្ដាយ?

ឌៀ៖ ម្ដាយឈ្មោះណាប់ ហឿន ។

វណ្ណៈ គាត់សព្វថ្ងៃស្លាប់ឬរស់?

ឌៀ៖ ស្លាប់ហើយ ។

វណ្ណៈ ទើបតែស្លាប់ក្រោយ៧៩ទេ?

ឌៀ៖ ស្លាប់បាន៣ឆ្នាំហើយ ។

វណ្ណៈ គាត់អាយុបានវែងៗដែរអញ្ចឹង ។ ចុះបងប្អូនបង្កើតរបស់មីង?

ឌៀ៖ បងប្អូនបង្កើតមានតែ២នាក់ ។

វណ្ណៈ តិចហ្នឹង?

ឌៀ៖ ចា៎!

វណ្ណៈ សព្វថ្ងៃនៅរស់ទាំងអស់?

ឌៀ៖ គាត់នៅឆ្ងាយ នៅស្រុកក្រោម ។

វណ្ណៈ ស្រុកក្រោមនៅណាទៅ?

ឌៀ៖ នៅលិ ។

វណ្ណៈ ស្រុកកំណើតកើតជាហ្នង កន្លែងមីងកើតនៅណា?

ឌៀ៖ នៅនេះឯង ។

វណ្ណៈ នៅភូមិអី?

ខៀៈ នៅភូមិដើងវត្ត ។

វណ្ណៈ ឃុំ?

ខៀៈ ឃុំព្រះនេត្រព្រះ ។

វណ្ណៈ ស្រុក?

ខៀៈ ស្រុកព្រះនេត្រព្រះ ។

វណ្ណៈ ខេត្តបន្ទាយមានជ័យ?

ខៀៈ ចាំ!

វណ្ណៈ ពីដើមខេត្តបាត់ដំបង?

ខៀៈ ចាំ! ពីដើមខេត្តបាត់ដំបង ។

វណ្ណៈ ឥឡូវបន្ទាយមានជ័យ?

ខៀៈ ចាំ!

វណ្ណៈ កាលពីតូចមីងរៀនបានដល់ណាដែរមីង រៀនសូត្រ?

ខៀៈ រៀនបានថ្នាក់ទី២ ។

វណ្ណៈ ពីដើមគេរាប់ពីធំមកមុន អញ្ចឹងមីងរៀនបានប៉ុន្មានឆ្នាំ?

ខៀៈ ថ្នាក់ទី១២ ។

វណ្ណៈ ម៉េចបានជាមីងឈប់រៀនត្រឹមថ្នាក់ទី១២?

ខៀៈ រវល់មើលប្អូនផង ឃ្វាលគោផង ព្រោះយើងអ្នកស្រែ ។

វណ្ណៈ មិនមែនឈប់ដោយសារសង្គ្រាមទេ?

ខៀៈ អត់ទេ អត់មានសង្គ្រាមទេ ។

វណ្ណៈ ឈប់ជួយធ្វើការឪពុកម្តាយអញ្ចឹង?

ខៀៈ ចាំ!

វណ្ណៈ មីងឈប់រៀននៅឆ្នាំណា?

ខៀៈ មិនដឹងទេ មិនស្គាល់ទេ ។

វណ្ណៈ ឈប់រៀនប៉ុន្មានឆ្នាំបានខ្មែរក្រហមចូល?

ខៀៈ មិនដឹងទេ មិនដឹងថាឈប់ប៉ុន្មានឆ្នាំទេ ។

វណ្ណៈ អញ្ចឹងកាលហ្នឹងមីងរៀនហ្នឹង ក្រោយមកមានទម្លាក់គ្រាប់បែកមានអីហ្នឹងមីងដឹងទេ?

ឌៀ៖ មានទម្លាក់គ្រាប់បែក ។

វណ្ណៈ សម័យទម្លាក់គ្រាប់បែកហ្នឹងមីងឈប់រៀននូវ?

ឌៀ៖ សម័យលន់ នល់ ។

វណ្ណៈ ឈប់រៀននូវ?

ឌៀ៖ ឈប់ហើយ សម័យលន់ នល់ ទម្លាក់គ្រាប់បែកហើយ ។

វណ្ណៈ មីងនៅណាកាលសម័យលន់ នល់ ទម្លាក់គ្រាប់បែក?

ឌៀ៖ នៅនេះឯង នៅផ្ទះចាស់នេះឯង ។

វណ្ណៈ ឈប់រៀននៅជួយធ្វើការឪពុកម្តាយ អត់មានទៅព្រៃ អត់មានចេញតស៊ូចេញអីទេ?

ឌៀ៖ អត់ទេ មិនដែលស្គាល់ផង ។

វណ្ណៈ ព្រោះអីនៅតូចៗដែរ?

ឌៀ៖ ចា៎! កាលអាពត ចូលមកខ្ញុំអាយុ១៣ឆ្នាំ នៅតូច ។

វណ្ណៈ អញ្ចឹងដល់ពេលខ្មែរក្រហមចូលមកក្នុងភូមិក្នុងស្រុកនៅឆ្នាំ១៩៧៥នេះ ដែលចូលមកខាងលន់ នល់ចាញ់ ហើយដល់ពេលចាញ់អញ្ចឹងចាញ់ខាងខ្មែរក្រហមអញ្ចឹង ចុះចូលជាមួយខាងខ្មែរក្រហមអញ្ចឹង តើមីងនៅក្នុងភូមិហ្នឹងដដែលឬក៏ជម្លៀសចេញទៅណា?

ឌៀ៖ ជម្លៀសឲ្យទៅនៅនោះ ទៅនៅភូមិតាប៉ែន ។

វណ្ណៈ ៧៥ជម្លៀសប្រជាជន អញ្ចឹងនៅភូមិឃុំហ្នឹងអត់មានប្រជាជនរស់នៅទេអញ្ចឹង?

ឌៀ៖ គេមកនៅភូមិយើង យើងទៅនៅភូមិគេ ។

វណ្ណៈ មីងជម្លៀសចេញទៅណា?

ឌៀ៖ ទៅកន្លែងទំនប់ភូមិប៉ែន ។

វណ្ណៈ ឆ្ងាយពីហ្នឹងទេតាប៉ែន?

ឌៀ៖ ចុងភូមិ ។

វណ្ណៈ ប៉ុន្មានគីឡូពីផ្ទះមីង?

ឌៀ៖ មិនដឹងប៉ុន្មានគីឡូទេ ឆ្លងភូមិទៅដល់នោះ ។

វណ្ណៈ ទៅភូមិតាប៉ែនរយៈពេលប៉ុន្មានខែប៉ុន្មានឆ្នាំបានត្រលប់មកវិញ?

ឌៀ៖ នៅទាល់តែយួនចូល ។

វណ្ណៈ អញ្ចឹងអត់នៅនេះទេ?

ឌៀ៖ អត់ទេ មិនបាននៅនេះទេ ។

វណ្ណៈ ៧៥ដល់៧៩យួនចូលហ្នឹង ហើយនៅហ្នឹងរហូត?

ខៀៈ ខ្ញុំនៅកងចល័ត ខ្ញុំគេបញ្ជូនទៅចល័ត ខ្ញុំអត់មានបាននៅជុំឪពុកម្ដាយទេ ។

វណ្ណៈ ឆ្នាំ៧៥ហ្នឹងគេឲ្យទៅកងចល័ត?

ខៀៈ ចា៎! ធ្វើកងចល័តតាំងពីអាយុ១៣ឆ្នាំ ។

វណ្ណៈ មីងអាចនិយាយបានទេថា កងចល័តធ្វើម៉េចខ្លះ ហើយមីងរៀបរាប់ទៅចាំខ្ញុំសួរតាមក្រោយទៀត ។

ខៀៈ កងចល័តហ្នឹងគេឲ្យរែកដី លើកទំនប់ អាទំនប់ត្រពាំងថ្ម អាងត្រពាំងថ្មអាធំហ្នឹង ពួកខ្ញុំរែកដីគ្រាន់តែអត់ទឹកមួយអាទិត្យ អត់មានទឹកផឹកទេ ទឹកមួយបំពង់ផឹកគ្នា១០នាក់ ហើយរែកទៅទៀតទៅអត់មានទឹកងូតទេ រែកដីរហូតទាល់តែរួចទំនប់ ហើយយើងដើរមកទាំងយប់ទៀតដើរគេឲ្យបញ្ជូនមកនៅតាមជ្រុងៗទៀត រួចគេឲ្យមកទាំងយប់ រួចថ្ងៃមកទាំងថ្ងៃ ដើររហូតកងចល័តមានអីមានតែរែកដីហ្នឹង បិទភ្លឺ បិទទំនប់ ។

វណ្ណៈ អញ្ចឹងដូចថា មុនទៅត្រពាំងថ្មហ្នឹងតើមីងទៅធ្វើកងចល័តធ្វើស្រែនៅណាសិនទេ ឬមួយចូលទៅកងចល័តទៅត្រពាំងថ្មតែម្ដង?

ខៀៈ ទៅត្រពាំងថ្មតែម្ដង គេបញ្ជូនទៅនោះ ។

វណ្ណៈ ចុះត្រពាំងថ្មគេចាប់ធ្វើតាំងពីឆ្នាំណាទៅ?

ខៀៈ មិនដឹងទេ ខ្ញុំមិនសូវដឹងទេ មិនដឹងឆ្នាំណាទេព្រោះយើងនៅតូចៗដែរ ។

វណ្ណៈ ចុះអាពត ដូចថាបាយរួមនូវ?

ខៀៈ បាយរួមហើយ បាយរួមរហូត ។

វណ្ណៈ អញ្ចឹងទៅកងចល័តត្រពាំងថ្មហ្នឹង ៧៥ខ្មែរក្រហមចូលមកហ្នឹងដែលចូលកងចល័តហ្នឹងទៅហ្នឹង អញ្ចឹង?

ខៀៈ ចា៎!

វណ្ណៈ ៧៥ដល់ឆ្នាំណាបានហើយទំនប់ត្រពាំងថ្ម?

ខៀៈ លើកកន្លះខ្សែរួច លើកកន្លះខ្សែរួចទំនប់ត្រពាំងថ្ម ដល់ពេលរួចគេឲ្យយើងមកនៅដើមពោធិ៍៣ដើម ហើយមកលើកទំនប់ដើមពោធិ៍៣ដើមទៀត ។

វណ្ណៈ អាចមីងប្រឡំ ដើមពោធិ៍៣ដើមអាចលើកមុន ត្រពាំងថ្មគេលើក២-៣ឆ្នាំ ឮថាគេលើក២-៣ ឆ្នាំដល់យួនជិតចូលមក ព្រោះអាងត្រពាំងថ្មហ្នឹងធំ ។

ខឿៈ ខ្ញុំទៅលើកតែកន្ទះខែ ពួកខ្ញុំគេបញ្ជូនទៅកន្ទះខែ ព្រោះអីគេផ្លាស់ថ្មីទៅទៀតណា៎ វាមានដោយកងមួយវគ្គៗ យើងលើកចែកដូចថាកងយើងអញ្ចឹងគេឲ្យលើកមួយកំណាត់ណា៎ លើករួចកងគេចូលមកលើកទៀត ។

វណ្ណៈ មីងទៅលើកនៅអាងត្រពាំងថ្មបានប្រហែលជាប៉ុន្មានខែ?

ខឿៈ ខ្ញុំលើកកន្ទះខែហ្នឹង ។

វណ្ណៈ តែកន្ទះខែទេ?

ខឿៈ ចា៎! បានកន្ទះខែគេបញ្ជូនឲ្យមកវិញ កន្ទះខែដាច់ទឹកដាច់ស្មៅក្រិន វាអត់មានទឹក កុំអីគេអត់ឆាប់បញ្ជូនទេ ដោយសារតែវាអត់មានទឹក អត់មានទឹកឲ្យផ្ញួត អត់បានផ្ញួតទឹកផង កន្ទះខែអត់ទឹកឲ្យយើងផ្ញួត ។

វណ្ណៈ អញ្ចឹងកាលពី៧៩ទៅ ដូចថាពីណាប្រធានសហករណ៍ ប្រធានឃុំ?

ខឿៈ ប្រធានសហករណ៍នៅនេះ ខ្ញុំមិនសូវបាននៅផ្ទះខ្ញុំអត់ដឹងទេ ខ្ញុំដើរតែចល័ត ។

វណ្ណៈ ចុះប្រធានឃុំ?

ខឿៈ ប្រធានឃុំឈ្មោះ តាក្រុក ឆាប់បាត់ហើយ ។

វណ្ណៈ ម៉េចបានជាឆាប់?

ខឿៈ មិនដឹងទេ ។

វណ្ណៈ តាក្រុក ហើយពីណាទៀត?

ខឿៈ អត់ស្គាល់ទេ ស្គាល់តែប៉ុណ្ណឹងឯង ។

វណ្ណៈ ចុះស្គាល់ យាយចែម ទេ?

ខឿៈ យាយចែម គាត់អត់មាននៅនេះទេ យាយចែម ដូចឮថានៅណាទេ តែខ្ញុំមិនទាន់បានឃើញមុខផង មិនដែលឃើញទេ ។

វណ្ណៈ ចុះខាងនារីគឺខាងអីមកហ្នឹងមីង?

ខឿៈ នារីច្រើន មកអញ្ចឹងខ្ញុំស្គាល់តែបន្តិចៗហ្នឹង ព្រោះខ្ញុំមិនសូវនៅផ្ទះគេបញ្ជូនទៅចល័ត ។

វណ្ណៈ ឥឡូវមីងថា៧៩ហ្នឹងចូលកងចល័ត គេបញ្ជូនទៅត្រពាំងថ្ម ពីណាបញ្ជូនមីងទៅត្រពាំងថ្ម?

ខឿៈ ពួកខាងសហករណ៍ ពួកឃុំណា៎ គេបញ្ជូនគេរើសយកទៅ គេថាមាននារីប៉ុន្មាននាក់ៗគេរើសយកទៅ គេរើសបញ្ជូនទៅ ។

វណ្ណៈ គ្នាច្រើនទេទៅត្រពាំងថ្មហ្នឹង?

ខឿៈ គ្នាច្រើន ។

វណ្ណៈ ប្រហែលជាប៉ុន្មាននាក់ដែរ?

ខៀ: លាយចំរុះ ខ្ញុំទៅនៅជាមួយគេអត់ស្គាល់ទេ មានតែភូមិគេភូមិខ្លួនឯងនេះអត់មានទៅផង ទៅតែម្នាក់ឯង ។

វណ្ណៈ លាយជាមួយភូមិគេ?

ខៀ: ចា៎! លាយជាមួយភូមិគេ ។

វណ្ណៈ ចុះម៉ាក្រុមម៉ាកងមីងហ្នឹងប្រហែលជាប៉ុន្មាននាក់?

ខៀ: ម៉ាកង១០០នាក់ ។

វណ្ណៈ ម៉ាកងមីងមាន១០០នាក់?

ខៀ: ចា៎!

វណ្ណៈ ១០០នាក់ហ្នឹងពីណាគេដឹកនាំ ប្រធាន?

ខៀ: ឈ្មោះស្អីទេ ឈ្មោះបង បឿន ស្រីប្រធានកងរយ ។

វណ្ណៈ ឥឡូវគាត់នៅទេ?

ខៀ: អត់ដឹងទេ ។

វណ្ណៈ ប្រធានកងរយ?

ខៀ: ចា៎! កងរយ ។

វណ្ណៈ ប៉ុន្តែអានេះម៉ាកងរបស់មីងទេ មានកងផ្សេងៗទៀតច្រើនទៀត?

ខៀ: ចា៎! ច្រើនណាស់ ។

វណ្ណៈ មនុស្សខ្លាប់ពេញអាងហ្នុង?

ខៀ: ច្រើនណាស់ រាប់មិនត្រូវទេ មិនស្គាល់ទេ ស្គាល់តែកងខ្លួនឯង ។

វណ្ណៈ អញ្ចឹងកាលមីងលើកហ្នឹងជួបការលំបាកយ៉ាងម៉េចខ្លះទៅ កាលលើកអាងត្រពាំងថ្មហ្នឹង?

ខៀ: លើកហ្នឹងបើយើងមិនរួចម៉ែត្រគីបទេ ក៏គេមិនឲ្យយើងឈប់ដែរ គេវាស់ឲ្យយើង២ម៉ែត្រ ២ម៉ែត្របណ្តោយ ហើយជម្រៅ១ម៉ែត្រ បើយើងធ្វើមិនរួចគេមិនឲ្យបាយយើងស៊ីទេ ។

វណ្ណៈ អញ្ចឹងប្រហែលជា៣ម៉ែត្រគីប?

ខៀ: ចា៎! ៣ម៉ែត្រគីប រែកទាល់តែរួចបានគេឲ្យបាយយើងស៊ី បើយើងរែកមិនរួចយើងឈឺ យើងរាងទំរន់ឈឺតិចៗអីគេហៅវៃចោលហើយ យប់ឡើងបាត់ខ្លួនៗ មិនដឹងរឿងអី ។

វណ្ណៈ យប់ឡើងបាត់ខ្លួន?

ខៀ: ហ្នឹងហើយ ។

វណ្ណៈ	ហើយកងរបស់មីងមានបាត់ទេ កងជាមួយមីង១០០នាក់ហ្នឹងមានបាត់ខ្លួនខ្លះទេ?

ខៀ:	បាត់ដែរ គេបញ្ជូនទៅនេះទៅនោះ តែមិនដឹងថាគេបញ្ជូនទៅខាងណា ។

វណ្ណៈ	មីងមានស្គាល់ឈ្មោះទេអ្នកបាត់ខ្លួនហ្នឹង?

ខៀ:	អត់មានស្គាល់ទេ ។

វណ្ណៈ	អត់មានស្គាល់ទេ?

ខៀ:	ចាំ! ព្រោះសុទ្ធតែពួកអ្នកថ្មី ពួកអ្នកមកពីភ្នំពេញ ។

វណ្ណៈ	អញ្ចឹង៧៥-៧៦ហ្នឹងពួកភ្នំពេញមកហើយ?

ខៀ:	ចាំ! នៅជុំគ្នា នៅលើកជាមួយគ្នាហ្នឹង ច្រើនតែវ័យកណ្ដាលទេដែលបាត់ខ្លួន ពួកដែលបានប្រពន្ធហើយធ្វើការ ច្រើនតែបាត់អញ្ចឹង ខ្លះគេចោទថាយើងយួនថាអីអញ្ចឹងណាំ ។

វណ្ណៈ	អញ្ចឹងអ្នកដែលបានប្រពន្ធហើយច្រើនតែបាននៅក្នុងភូមិ?

ខៀ:	គេបញ្ជូនដែរហ្នឹង អត់សូវបាននៅក្នុងភូមិទេ កូន១កូន២អត់សូវបាននៅទេ ចល័តដែរហ្នឹង ។

វណ្ណៈ	កូន១កូន២ទៅកងចល័តដែរ?

ខៀ:	ចាំ!

វណ្ណៈ	ទៅអាងត្រពាំងថ្មហ្នឹងដែរ?

ខៀ:	ទៅអាងត្រពាំងថ្ម ទំនប់តាវ៉ាល់ ។

វណ្ណៈ	អញ្ចឹងឥឡូវខ្ញុំសួរអាងត្រពាំងថ្មសិន អាងហ្នឹងយើងទៅកន្លែងអាងត្រពាំងហ្នឹង បានន័យថាអាងត្រពាំងគួរតែមានទឹកច្រើន ហេតុអីបានជាអត់មានទឹកដឹកអញ្ចឹង?

ខៀ:	អានោះយើងទៅលើក យើងទើបតែទៅលើកបានម្ដង យើងទៅលើកកំពស់ឡើងពាក់កណ្ដាលដើមត្នោត ពាក់កណ្ដាល ។

វណ្ណៈ	ហើយទទឹងប្រហែលប៉ុន្មាន ទទឹងធំទេ?

ខៀ:	ធំណាស់ ជិះទៅមើលម្ដងទៅ ។

វណ្ណៈ	ចាំសម្ភាសន៍មីងហើយចាំទៅមើល ។

ខៀ:	ទៅមើលទៅ ឡើងសន្ទឹម គេថាទឹកឡើងកាច ។

វណ្ណៈ	គេថាលើកប៉ុន្មានឆ្នាំបាន ថាលើក២-៣ឆ្នាំបានៗត្រពាំងហ្នឹង ។

ខៀ:	មិនដល់២-៣ឆ្នាំទេទំនប់ហ្នឹង មិនដល់មួយឆ្នាំផងដឹង ខ្ញុំលើកតែកន្លះខែរួចមួយដុង ហើយគេបន្តទៅទៀត ហើយខ្ញុំក៏មិនទាន់ឃើញកន្លែងដែលលើកហ្នឹងមិនទាន់ដែរឃើញទេ ឃើញតែកូនក្មេងទៅលេង ទឹកឡើងពេញហ្នឹង ។

វណ្ណៈ ហ្នឹងហើយ ឥឡូវកន្លែងគេលេងសប្បាយ ។

ឌៀ: ផាប់ច្រើនណាស់ ទ្រាប់បាតទំនប់មិនចេះតិចទេ ។

វណ្ណៈ ម៉េចទ្រាប់បាតទំនប់?

ឌៀ: គេវ៉ៃចោលដាក់កប់ក្រោមទំនប់ បើមិនអញ្ចឹងវាអត់ជាប់ទេ វាថាទាល់តែមានខ្មោចកាន់បានជាប់ ។

វណ្ណៈ អញ្ចឹងទៀត?

ឌៀ: ចា៎! វ៉ៃចោលមិនតិចទេ ។

វណ្ណៈ វ៉ៃចោលហើយកប់ក្រោមទំនប់?

ឌៀ: ចា៎!

វណ្ណៈ ម៉េចបានជាមីងដឹង?

ឌៀ: ពួគេថាដែរ គេប្រាប់អញ្ចឹងឯង ពួគេថាបើអត់កប់មនុស្សទេវាអត់ជាប់ ទំនប់ហ្នឹងវាអត់ជាប់ វាមានមេ ថាមេវាកាន់ ។

វណ្ណៈ ចុះវ៉ៃចោលហ្នឹង ភាគច្រើនអ្នកទាំងអស់ហ្នឹងខុសអី?

ឌៀ: ខុសដូចថាយើងរាងខ្ជិល ដែលយើងអ្នកថ្មីនៅភ្នំពេញអញ្ចឹងមិនធ្លាប់នឿយ ដល់ពេលយើងមក នៅវែកដីស៊ីអត់អញ្ចឹង ក៏វាធុញវាថប់ ដល់ពេលអញ្ចឹងវាចេះតែខ្ជិលប្រអូសទៅ មិនទៅ ធ្វើ ឈឺធ្វើអីទៅ គេសង្កេតៗថាយើងនេះខ្ជិល គេតាមដានយើង ដល់ពេលគេស៊ើបប្រវត្តិយើងទៅថាយើងនេះជាប់យួនផង ក៏គេយកយើងទៅវ៉ៃចោលទៅ ។

វណ្ណៈ បើស៊ើបប្រវត្តិថាជាប់ធ្វើការលន់ នល់ ក៏វ៉ៃចោលទៀត?

ឌៀ: ចា៎! ធ្វើការចេះអីណា៎ ពូអើយខ្ញុំមិនសូវចេះខាងនិស្សិតអីគេនោះ គេវ៉ៃចោល ។

វណ្ណៈ គេស្រាវជ្រាវជាប់និស្សិតអីគេវ៉ៃចោលដែរ?

ឌៀ: ចា៎! ឲ្យតែអ្នកចេះ ។

វណ្ណៈ អញ្ចឹងភាគច្រើនស្លាប់ដោយសារវ៉ៃចោល ឬក៏ស្លាប់ដោយសារអត់អាហារអត់ទឹក?

ឌៀ: អត់អាហារមិនសូវទេ ភាគច្រើនវ៉ៃចោល គ្រាន់តែក្នាលួចរត់មកផ្ទះ ប្រជុំទាញកាំភ្លើងបាញ់ចោលមុខប្រជាជនយើងដែលកំពុងប្រជុំហ្នឹង អាខ្លះមិនទាន់បាញ់ផងក៏សន្លប់មុន ភ្នាក់ភ័យ រត់មកផ្ទះព្រោះវានឿយហត់ វារត់មកផ្ទះ ។

វណ្ណៈ រត់មកផ្ទះទៅវិញគេចាប់យកហ្នង?

ខឿៈ ចាំ! គេចាប់បានក៏គេបាញ់ចោលមុខ ខ្ញុំអង្គុយប្រជុំអញ្ចឹងឯង គេហៅទៅប្រជុំយប់ លេង ទាញកាំភ្លើងបាញ់ អាមួយនោះរត់ ដល់ពេលរត់ទៅបាញ់ភ្លើងឲ្យចំ ហើយបាញ់គ្រាប់ពីក្រោយ ព្រុសៗទាំងពីរ ។

វណ្ណៈ ឈ្មោះអីអ្នកងាប់ហ្នឹង?

ខឿៈ មិនស្គាល់ទេ កងចល័តដូចគ្នា ។

វណ្ណៈ តែអ្នកភ្នំពេញឬក៏មូលដ្ឋានយើង?

ខឿៈ ច្រើនតែអ្នកភ្នំពេញ ហៅខ្ញុំទៅប្រជុំ ខ្ញុំញ័រខ្លួនគគ្រឹក ។

វណ្ណៈ អញ្ចឹងមុនបាញ់ចោលហ្នឹងហៅអ្នកកងចល័តឲ្យមកមើលទៀត?

ខឿៈ ហៅឲ្យមើល ។

វណ្ណៈ ហៅឲ្យមើលហ្នឹងគេប្រកាសថាម៉េចទៅ?

ខឿៈ គេប្រកាសថាកុំធ្វើតាម យើងធ្វើការរត់ចោលជួរគេត្រូវតែបាញ់ចោល ខ្ញុំក៏រត់ដែរតែគេអត់បាញ់ចោល តែគេគ្រាន់តែចាប់ចងហើយវ៉ៃ ស៊ូមិនបានក៏រត់មករកម៉ែរកឪ ម៉ែឪជួយណារួច គេបញ្ជូនទៅវិញ ដល់គេបញ្ជូនទៅវិញអានោះឯងគេសម្លាប់យើងចោល ។

វណ្ណៈ ចុះមីង គេចាប់មីងចងចាប់ចងនៅណា នៅអាងត្រពាំងថ្មដែរឬក៏នៅណា?

ខឿៈ នៅក្រសាំងអត់គ្រាប់ ។

វណ្ណៈ នៅក្រសាំងអត់គ្រាប់វិញ?

ខឿៈ ចាំ!

វណ្ណៈ អញ្ចឹងចាំខ្ញុំសួរទាក់ទងនឹងក្រសាំងអត់គ្រាប់ទៀត តើវាយ៉ាងម៉េចកន្លែងហ្នឹងធ្វើការលំបាកដូច នៅអាងត្រពាំងថ្មដែរឬក៏ម៉េច?

ខឿៈ ដូចគ្នា លើកទំនប់ដូចគ្នា ទំនប់ក្រសាំងអត់គ្រាប់ ។

វណ្ណៈ អញ្ចឹងមីងសង្កេតឃើញថា មនុស្សស្លាប់នៅអាគត្រពាំងថ្មច្រើន ហើយដូចថាពេលដែលយើង ធ្វើមិនហើយហ្នឹងតើគេឲ្យបបរយើងហូបដែរអត់?

ខឿៈ គេមិនឲ្យស៊ីទេ ។

វណ្ណៈ បបរគេឲ្យយើងហូបឆ្អែតអត់ បាយឆ្អែតបបរឆ្អែតទេ?

ខឿៈ បើយើងធ្វើការខ្លាំងគេឲ្យហូបឆ្អែត បាយម្ហូបដឹងតែទឹកប្រហុកហើយនឹងអំបិល ។

វណ្ណៈ បាយឲ្យឆ្អែតដែរ?

ខៀវៈ ចាំ! តែរកទឹកដឹកអត់មានទេ ដឹកមួយបំពង់១០នាក់ ។

វណ្ណៈ អញ្ចឹងអត់មានទឹកមុជទេ?

ខៀវៈ អត់មានទេ ហើយចៃចេញពេញខ្លួនព្រោះយើងអត់មានទឹក កូនខ្ញុំអីនិយាយគេមិនជឿទេ ។

វណ្ណៈ ចុះមីង ឧបមារថាយើងធ្វើការអញ្ចឹង នៅកន្លែងកងចល័ត នៅកន្លែងទំនប់អាងត្រពាំងថ្មហ្នឹង តើគេមានរោងឲ្យយើងស្នាក់នៅដែរអត់?

ខៀវៈ គេធ្វើរោងឲ្យយើងដេក ហើយដេកនៅលើដីហ្នឹងឯង ។

វណ្ណៈ អត់មានកន្ទេលក្រាលទេ?

ខៀវៈ កន្ទេលយើងមានស្ពាយតាមខ្លួន កន្ទេលក៏ស្ពាយ ហើយមុងក៏ស្ពាយ ។

វណ្ណៈ ចុះបើមានភ្លៀងធ្លាក់អីអរទេ?

ខៀវៈ ភ្លៀងធ្លាក់ទទឹក ហើយមានតែមួយកន្លែងហ្នឹងឯងអត់ទឹក ក្រៅពីនោះមិនអត់ទេ មានតែអាងត្រពាំងថ្មនោះឯងដែលអត់មានទឹក ដល់ពេលមកនេះមានទឹកដឹក មានទឹកងូត ។

វណ្ណៈ អញ្ចឹងមីងអត់បានធ្វើអាងត្រពាំងថ្មរហូតដល់ធ្វើហើយជាស្ថាពរទេ មិនបានទេ?

ខៀវៈ មិនបានទេ គ្រាន់តែលើករួចមួយកំណាត់ទៅគេបញ្ជូនយើងមកកងនោះ ដូចថាគេដាក់ឲ្យយើងមួយកំណាត់ទៅ យើងរួចមួយកំណាត់ហ្នឹងគេបញ្ជូនយើងទៅកន្លែងផ្សេងទៀត ហើយកងគេមកធ្វើបន្តទៀតទៅ វាអញ្ចឹងឯង ។

វណ្ណៈ ចុះប្រធានដឹកនាំមីងហ្នឹង ឈ្មោះអីម៉េញ?

ខៀវៈ ឈ្មោះ បឿន ។

វណ្ណៈ អញ្ចឹង បឿន ហ្នឹងត្រូវដឹកមួយក្រុមហ្នឹងមកកន្លែងផ្សេងទៀត?

ខៀវៈ ចាំ! កងរយ ។

វណ្ណៈ អញ្ចឹង កន្លែងហ្នឹងខ្ញុំឆ្ងល់ដែរ មូលហេតុអីបានគេឲ្យមីងធ្វើតែក្រុមមីង ១០០នាក់ហ្នឹងធ្វើតែកន្ទះខែ?

ខៀវៈ ខ្ញុំបានធ្វើតែកន្ទះហ្នឹងឯង អត់បានធ្វើយូពេក ។

វណ្ណៈ ទាំង១០០នាក់ហ្នឹង ក្រុមមីងទាំងអស់ហ្នឹង?

ខៀវៈ ចាំ!

វណ្ណៈ ឬមកតែមីងមួយ?

ខៀវៈ ទេ មកទាំងអស់គ្នា ហើយដើរយប់ទៀត អាខ្លះដើរដេកក៏លក់ស្ទុះទៅ ។

វណ្ណៈ អាងត្រពាំងហ្នឹងមានចម្ងាយពីហ្នឹងទៅឆ្ងាយទេ?

ខៀវៈ ខ្ញុំមិនស្គាល់ទេ ភ្លេចហើយ ។

វណ្ណៈ ចុះគេថាសម័យហ្នឹង ខ្ញុំសម្ភាសន៍មីងនោះថាមានពស់មានអីខាំក៏មានដែរអ្នកធ្វើនៅហ្នឹង?

ខៀវៈ ពស់ ដេក១០០នាក់អញ្ចឹងក្បាលទល់គ្នាអញ្ចេះ អានោះមិនមែនអាងត្រពាំងថ្មទេដូចនៅស្នាច់ដល់ពេលធ្វើច្រើនកន្លែងទៅវាភ្លេច មានពស់មានអី ពស់វាកាត់ខ្លួនពេលយើងកំពុងតែដេកហើយក្បាលទល់គ្នាអញ្ចឹងឯង ដេកជើងចេញក្រៅហើយក្បាលទល់គ្នា ដូចថាមីមួយដេកអត់ទាន់ដេកលក់ទេ ហើយក្រៅពីហ្នឹងលក់អស់ហើយ ហើយឃើញពស់វាកាត់ខ្លួនអញ្ចឹងវាស្រែកពស់...ហើយទាំងអាអ្នកដេកលក់ហ្នឹងក៏ស្រែកពស់ ស្រែកពស់ទាំងអស់គ្នា ដល់ហើយក៏ផ្អើលរត់មកមើលពស់ ពស់តែមួយហើយនាំគ្នាសួរថាឯណាពស់ ដល់ហើយថាអត់ដឹងទេ ភ្លេចពោះព្រោះពស់ទាំងអស់គ្នា ផ្អើល ។

វណ្ណៈ អញ្ចឹងផ្អើលអញ្ចឹងគេអត់ថាអីទេ?

ខៀវៈ គេអត់ថាអីទេ ។

វណ្ណៈ គណៈគ្រប់គ្រងអីគេអត់ថាអីទេ?

ខៀវៈ គេអត់ថាអីទេ គេចូលមើលទៅក៏គេវិះទៅ ។

វណ្ណៈ ចុះមីង កាលហ្នឹងមីងអត់មានស្គាល់គណៈតំបន់ គណៈភូមិភាគអីទេ?

ខៀវៈ ខ្ញុំនៅត្រពាំងថ្មមិនដឹងអ្នកណាកាន់កាប់ទេ ។

វណ្ណៈ មីងដឹងតែធ្វើការ?

ខៀវៈ ដឹងតែធ្វើការ ហើយដឹងតែប្រធានកងវយ ។

វណ្ណៈ អត់ស្គាល់រស់ ញឹម អីទេ?

ខៀវៈ អត់ស្គាល់ទេ ស្គាល់តែ តាសំអាត ហើយនឹងតាម៉ោង ។

វណ្ណៈ តាម៉ោង ធ្វើអី?

ខៀវៈ តាម៉ោង ទំនប់រនុះបាញ់ ហើយតាសំអាត ដូចជាកាន់ពួកខ្ញុំ ។

វណ្ណៈ តាម៉ោង ហើយនឹងតាសំអាតហ្នឹងគាត់មកពីខាងណាវិញ?

ខៀវៈ មិនដឹងទេ សុទតែពួកនិយាយអាហ្នឹងៗ មិនដឹងមកពីខាងណាទេ តែរាងចំណាស់ៗហើយពួកតាហ្នឹង ។

វណ្ណៈ ចុះមីងចេញពីអាងត្រពាំងថ្មមក ចុះមកធ្វើអាងទំនប់ទៀត?

ខៀវៈ ធ្វើទំនប់ក្រសាំងអត់គ្រាប់ ។

វណ្ណៈ ទំនប់ក្រសាំងអត់គ្រាប់?

ខ្សៀ:	ចា៎!

វណ្ណៈ	គេដាក់អញ្ចឹងហ្នង?

ខ្សៀ:	ចា៎!

វណ្ណៈ	ចុះឥឡូវគេហៅអីវិញ?

ខ្សៀ:	ក្រសាំងអត់គ្រាប់អញ្ចឹង ក្រសាំងវាអត់មានគ្រាប់ ។

វណ្ណៈ	កន្លែងហ្នឹងសំបូរដើមក្រសាំងអញ្ចឹង?

ខ្សៀ:	ក្រសាំងមានច្រើន តែក្រសាំងហ្នឹងវាអត់មានគ្រាប់ គេហៅតែក្រសាំងអត់មានគ្រាប់ ។

វណ្ណៈ	ដល់ហើយមកធ្វើហ្នឹង តើគេមានផែនការដូចថាដាក់ផែនការមួយថ្ងៃ៣ម៉ែត្រគីបអីទៀតទេ?

ខ្សៀ:	ដាក់ដូចតែគ្នាអញ្ចឹង ។

វណ្ណៈ	ដាក់ដូចគ្នា?

ខ្សៀ:	ចា៎!

វណ្ណៈ	ហើយមកលើកហ្នឹងប៉ុន្មាន មនុស្សច្រើនទេ?

ខ្សៀ:	ច្រើន ។

វណ្ណៈ	មានកងផ្សេងទៀត?

ខ្សៀ:	ចា៎! មានកងផ្សេងៗទៀត មនុស្សឡើងខាងវន្នីស តែមិនស្គាល់គេទេ ហើយកាលនោះនៅស្មើរផងមិនសូវចាំទេ កាលនោះបងខ្ញុំជាប់ប្រវត្តិទាហាន ទាហានសម័យលន់ នល់ គេចាក់រុកឯងឡូឯងទៅចល័ត ឯងប្រវត្តិទាហាន ហើយកាលហ្នឹងស្មើរណាស់ អាយុ១៣ឆ្នាំហ្នឹង

វណ្ណៈ	ចុះបងមីងទាហានមែន?

ខ្សៀ:	ទាហាន សុទ្ធតែទាហាន ។

វណ្ណៈ	ទាហានលន់ នល់?

ខ្សៀ:	ចា៎!

វណ្ណៈ	ចុះម៉េចបានដាគាត់រួចខ្លួន?

ខ្សៀ:	ងាប់អស់មួយនៅមួយងាប់ខ្លួនឯង ហើយគាត់នោះរួចខ្លួនគាត់រត់ទៅតំបន់៣ បងខ្ញុំបងបន្ទស់រត់ទៅតំបន់៣រួចខ្លួនរស់ ។

វណ្ណៈ	ហ្នឹងហើយគេថាតំបន់៣ស្រួល?

ខ្សៀ:	ចា៎! គាត់រត់ទៅតំបន់៣ ពីមុនរស់ទេ ដល់ពេលគេចាក់រុកថាឯងប្រវត្តិទាហាន គាត់និយាយពីខ្ញុំមិនដែលបាននៅភូមិទេ ។

វណ្ណៈ ចុះមីងមានបងប្អូនគេយកទៅវៃចោលដែរ?

ខៀៈ អត់ទេ ។

វណ្ណៈ ចុះមីងថាពីណានោះ?

ខៀៈ បងខ្ញុំដែលស្លាប់នោះ ស្លាប់សម័យលន់ នល់ ទេ ។

វណ្ណៈ ស្លាប់កាលធ្វើសង្គ្រាមទេ?

ខៀៈ ចា៎!

វណ្ណៈ ចុះដល់ពេលចូលសម័យប៉ុល ពត?

ខៀៈ អត់មានទេ ។

វណ្ណៈ មានមួយរត់ទៅតំបន់៣?

ខៀៈ ចា៎!

វណ្ណៈ ឈ្មោះអីរត់ទៅតំបន់៣ហ្នឹង?

ខៀៈ ឈ្មោះ ខាំ បានរស់មួយហ្នឹង ដែលនៅនេះងាប់ទាំងអស់ ពួកដែលជាប់ប្រវត្តិហ្នឹង គេចាក់ចូចវៃចោលអស់ហើយ ។

វណ្ណៈ នៅនេះសម័យខ្មែរក្រហមគេហៅតំបន់ប៉ុន្មាន?

ខៀៈ តំបន់៥ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ ចុះតំបន់៥ហ្នឹងដូចថាមីងអត់ស្គាល់ យាយចែម ទេ?

ខៀៈ ឮតែឈ្មោះតែមិនដឹងនៅណា ឮតែឈ្មោះ យាយចែមៗ តែមិនដឹងនៅណាផង អត់ទាន់ស្គាល់មុខផង អត់ដែលឃើញមុខទេ ។

វណ្ណៈ ចុះ តាក្រក អីក្រោយមកគេចាប់មីងដឹងទេ?

ខៀៈ មិនដឹងទេ យូរទៅស្រាប់តែបាត់ខ្លួនទៅតាក្រក ប្រធានស្រុកយើងនេះដូចជា តាញឹម ដល់ពេលយួនដេញមក អស់ពីពួកយើងដូចថា ដល់ក្រោយមកសុទ្ធតែនារតី ។

វណ្ណៈ ចុះឥឡូវកាលសម័យ តាក្រក មនុស្សស្លាប់ច្រើនទេ?

ខៀៈ ច្រើន ។

វណ្ណៈ ដល់ពេលពួកនារតីចូលមកលែងសម្លាប់ ឬក៏សម្លាប់ទៀត?

ខៀៈ សម្លាប់ទៀត ។

វណ្ណៈ សម្លាប់ទៀត?

ឌៀៈ ចាំ! សម្លាប់ទៀត ពីរជាន់ នារតីនៅកន្លែងដែល តាក្រុក នៅ នៅកន្លែងទីនេះបៀតភ្នំហ្នឹង ដល់ពេលយួនចូលមកក្បាល ខ្មោចឆ្អឹងខ្មោចឡើងគរ សុទ្ធតែខ្មោច ខ្មោចតូចខ្មោចធំ ។

វណ្ណៈ អញ្ចឹងគេយកវេីចោលហ្នឹងមានកន្លែងវេីចោលដែរ?

ឌៀៈ ឃើញទីនោះហើយ ខ្ញុំមកឃើញ ខ្ញុំចូលមកភូមិវិញ កាលយើងចូលមកភូមិវិញឃើញ ខ្ញុំដើរទៅព្រៃឃើញកន្លែង តាក្រុក ហ្នឹងឯង ឃើញក្បាលខ្មោចឡើងកំពេស ។

វណ្ណៈ កន្លែង តាក្រុក នៅមែន?

ឌៀៈ ចាំ!

វណ្ណៈ កន្លែងហ្នឹងគេហៅអី គេហៅមន្ទីរសន្តិសុខមែន?

ឌៀៈ កន្លែងហ្នឹងបើដូចយើងសព្វថ្ងៃគេហៅឃុំ តែពីដើមគេមិនមែនហៅឃុំទេ គេហៅសង្កាត់ណាំ មិនដឹងជាភូមិឬក៏សង្កាត់ទេចង់ភ្លេចហើយ ។

វណ្ណៈ អញ្ចឹងកន្លែងហ្នឹងមានកន្លែងដាក់មនុស្សទុកវេីចោលដែរ?

ឌៀៈ បែបប្រហែលជាបញ្ជូនទៅវេីចោលទីនោះក៏មិនដឹង ព្រោះឃើញខ្មោចឡើងកំពេស ។

វណ្ណៈ អញ្ចឹងខ្ញុំសួរមីងទៅកន្លែងទំនប់ក្រសាំងអត់គ្រាប់ហ្នឹង ទំនប់ហ្នឹងធ្វើធំដូចត្រពាំងថ្មដែរឬក៏ធ្វើតូចជាង?

ឌៀៈ វាងតូចជាងបន្តិច ។

វណ្ណៈ តូចជាងត្រពាំងថ្មទេ?

ឌៀៈ ចាំ!

វណ្ណៈ តូចជាងហ្នឹងមីងអាចថា ខ្ពស់ទំនប់ប៉ុណ្ណា ហើយកំពស់ប៉ុណ្ណា ហើយទឹងប្រវែងប៉ុន្មានដែរ?

ឌៀៈ ខ្ញុំភ្លេចហើយ មិនដឹងខ្ពស់ប៉ុន្មានម៉ែត្រ ខ្ពស់ប្រហែលជា២ម៉ែត្រ ។

វណ្ណៈ ២ម៉ែត្រតូចណាស់?

ឌៀៈ ទំនប់ក្រសាំងអត់គ្រាប់ហ្នឹងប្រហែលជា២ម៉ែត្រហ្នឹងឯង ។

វណ្ណៈ ចុះបើអាងត្រពាំងថ្មគេថាធំ?

ឌៀៈ អាងត្រពាំងថ្មប្រហែលជា៦ម៉ែត្រ គេថាបរឡានជៀសគ្នាកើតណាំ អាហ្នឹងអាងត្រពាំងថ្ម ។

វណ្ណៈ អាហ្នឹងអាងត្រពាំងថ្មហ្នឹងគេធ្វើសម្រាប់ស្តុបទឹកទុកធ្វើស្រែឬក៏យ៉ាងម៉េច?

ឌៀៈ ខ្ញុំមិនដឹងទេ ស្រាប់តែវាឲ្យលើកឡើងធំ កងខ្ញុំលើកចាក់ពីខាងនេះ ហើយខាងនោះគេលើកពីខាងនោះ អញ្ចឹងហើយបានទំនប់វាធំ ប្រហែលជា៦ម៉ែត្រ គេថាបើកឡានជៀសគ្នា ។

វណ្ណៈ ចុះទំនប់ក្រសាំងអត់គ្រាប់ហ្នឹងមួយថ្ងៃ៣ម៉ែត្រគឺបដូចគ្នា?

ខៀៈ ដូចគ្នា ។

វណ្ណៈ ហើយមានមនុស្សស្លាប់ច្រើនទេ ឬមួយក៏ធូរជាងអាងត្រពាំងថ្ម?

ខៀៈ ក្រសាំងអត់គ្រាប់ មិនសូវដឹងទេភ្លេចហើយ វាមានស៊ាប់វាមិនអត់នោះទេ ដូចថា..ខ្ញុំមិនសូវដឹងទេ ។

វណ្ណៈ ហូបចុកអីមិនអីទេ?

ខៀៈ ហូបចុកមានបាយតែវាអត់មានម្ហូប អត់តែម្ហូបមានតែបាយ ។

វណ្ណៈ ចុះមានយកវែរចោលមានអីដូចគ្នា?

ខៀៈ មានដូចតែគ្នាហ្នឹង ។

វណ្ណៈ ហ្នឹងមីងធ្វើហ្នឹងដល់ឆ្នាំណាទៅ ដូចថាធ្វើប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

ខៀៈ ទៅតែកន្លះខែហ្នឹង កាលនោះខ្ញុំភ្លេចហើយ មួយខែមិនដឹងកន្លះខែមិនដឹង គេចេះតែបញ្ជូនទៅ ហើយវាចេះតែភ្លេចទៅ ហើយទៅស្នាក់ទៅអីទៀត មិនដឹងឯណាទេភ្លេចអស់ហើយ ។

វណ្ណៈ ស្នាក់នៅខាងណាវិញទៅ?

ខៀៈ មិនដឹងទេ ខ្ញុំភ្លេចអស់ហើយ ទំនប់ស្នាក់ៗពូតែគេថា ។

វណ្ណៈ ទំនប់ស្នាក់ហ្នឹងធំដែរ?

ខៀៈ ធំដែរហ្នឹង អានោះលើកក្នុងព្រៃ ចំការព្រៃ យើងឆ្ការព្រៃបានកាប់បានលើកខ្លួនឯង យើងអត់ឆ្ការខ្លួនឯងទេគេមិនដឹងទេ ដឹងតែវាស់ឲ្យយើងហើយគឺហើយ អាហ្នឹងឆ្ការព្រៃបានលើកខ្លួនឯង គេវាស់តែដីឲ្យយើងរួចយើងឆ្ការព្រៃលើកខ្លួនឯង លើកចាក់ស្មឹង នៅនោះលើកចាក់ស្មឹង បិទស្មឹង ។

វណ្ណៈ ម៉េចបានជាបិទស្មឹងហ្នឹង?

ខៀៈ មិនដឹងម៉េច គេហៅស្មឹងស្នាក់ៗ លើកខាងនោះទៅលើកចាក់ពីខាងនោះ យើងលើកពីខាងនេះ លើកឲ្យពេញលើកបិទឲ្យជិត ។

វណ្ណៈ លើកបិទឲ្យជិតទៅ?

ខៀៈ ចាំ! បិទឲ្យជិតទឹកឡើងប្រួង ខ្លាំងមែនវាបញ្ជា ។

វណ្ណៈ អញ្ចឹងលើកនៅស្មឹងស្នាក់ហ្នឹងស្លាប់មនុស្សទេ?

ខៀៈ មិនដឹងទេ មិនសូវដឹងដែរ គេមិនសូវឲ្យយើងដឹងទេ ។

វណ្ណៈ ចុះប្រធានមីងដែលដឹកនាំនៅកន្លែងស្នាក់ហ្នឹងពីណាគេ បឿន ហ្នឹងដដែល?

ខៀៈ ដដែលហ្នឹង ។

វណ្ណៈ អត់មានគេចាប់គាត់ទៅណាទៅណីទេ?

ខៀៈ គេអត់មានចាប់ទេ ។

វណ្ណៈ រហូតដល់៧៩ហ្នឹង បឿន ហ្នឹងដដែល ហើយគាត់រត់ទៅណាពេលដែលយួនចូលមក?

ខៀៈ ខ្ញុំដុតពីនោះមកខ្ញុំរត់មកផ្ទះ គេបញ្ជូនខ្ញុំមកកងវ៉ានេះ ។

វណ្ណៈ អញ្ចឹងខ្ញុំចង់សួរមីងដែរ នៅកន្លែងក្រសាំងអត់គ្រាប់ហ្នឹង ហេតុអីបានជាគេចាប់មីងចង?

ខៀៈ ខ្ញុំរត់មកផ្ទះ ហើយរត់កាត់វាល រត់២នាក់ដល់ពេលខ្ញុំរត់ក្រោយគេភ្ញាក់ទាន់ មីមួយនោះវាទាញដៃអូសមក ហើយខ្ញុំថាមិនទៅទេៗ ដល់ពេលគេរត់រួចទៅនៅតែឯង វាទាញអូស អូសបាន២នាក់ ហើយគេចាប់ចង គេអត់សម្លាប់ទេ គេថាមនុស្សនេះវាមិនដែលចេះរត់ទេ គេនាំទេបានវារត់ កុំអីគេបាញ់ចោលបាត់ហើយ ។

វណ្ណៈ ពីណាជាអ្នកជួយនិយាយ?

ខៀៈ ដែលគេប្រធានដែលធ្លាប់ដឹង បងបឿន ធ្លាប់នៅជាមួយខ្ញុំ ។

វណ្ណៈ ហើយពីណាគេជាអ្នកចាប់ ឈ្លប?

ខៀៈ ទេ ពួកគាត់ហ្នឹងឯងចាប់ខ្លួនគាត់ ។

វណ្ណៈ ពួកគាត់ដែរហ្នឹង?

ខៀៈ ចាំ!

វណ្ណៈ ពួក បងបឿន ហ្នឹងដែរហ្នឹង?

ខៀៈ ចាំ!

វណ្ណៈ ពួកបងបឿន ហ្នឹងគាត់ដឹងម៉េចបានជាគាត់ចាប់?

ខៀៈ អ៊ំ! កាលនោះមិនមែន បងបឿន ទេឈ្មោះ នា នារតី នារតីចូលហើយ បងបឿន ហ្នឹងមិនដឹងជាផ្លាស់ទៅណាទេ កាលនោះពួកនារតីកាន់ក្តាប់ ។

វណ្ណៈ អញ្ចឹងផ្លាស់ បងបឿន ទៅចូល បងនា ស្រីឬក៏ប្រុស?

ខៀៈ ស្រី ។

វណ្ណៈ ចុះមីង ពេលគេចងមីងហ្នឹង គេចងរយៈពេលប៉ុន្មានទៅ មួយថ្ងៃឬក៏យ៉ាងម៉េច?

ខៀៈ ចងប្រហែលជាមួយម៉ោងហ្នឹងគេលែងវិញ គេថាឈប់រត់ណាំ រត់លើកក្រោយគេបាញ់ចោល ដល់ហើយឈប់រហូត ដល់ក្រោយមកទៀតគេបញ្ជូនមកកងវ៉ា មកនៅកងវ៉ាឲ្យបាញ់ថ្នាំកប្បាស ។

វណ្ណៈ	អញ្ចឹងកាលហ្នឹង កាលគេចងមីងហ្នឹងមីងមានបានរត់មកដល់ផ្ទះនៅ?

ឌឿៈ	មិនទាន់ដល់ទេ នៅនោះឯងមិនទាន់ចេញផុតផង មិនទាន់ចេញបាន១០ម៉ែត្រផង ។

វណ្ណៈ	អាហ្នឹងគ្រាន់តែចង់រត់ទេ?

ឌឿៈ	ចាំ!

វណ្ណៈ	អញ្ចឹងបើរត់មកដល់ផ្ទះ ហើយទៅវិញដឹងតែស្លាប់ហើយអញ្ចឹង?

ឌឿៈ	ដឹងតែស្លាប់ហើយ ។

វណ្ណៈ	ព្រោះអានេះអត់ទាន់រត់ផង គ្រាន់តែចង់រត់ហ្នឹង?

ឌឿៈ	ចាំ! គ្រាន់តែគេទាញដៃមកគេភ្ជាក់ទាន់ ដល់ពេលគេទាញដៃមីនោះក៏រត់រួច ចាប់បានតែឯង ។

វណ្ណៈ	ចុះម្នាក់ទៀតធ្វើម៉េចទៅ?

ឌឿៈ	ម្នាក់ទៀតគេរត់មកដល់ផ្ទះទៅ គេអត់បានទៅវិញទេ ដូចថាប្រធានភូមិគេជួយលាក់ក៏មិនដឹង ឬក៏បងប្អូនគេមានខ្សែជាមួយពួកនារតីក៏មិនដឹង ។

វណ្ណៈ	ម្នាក់ដែលរត់ជាមួយមីងហ្នឹងឈ្មោះអី?

ឌឿៈ	ឈ្មោះ សាវន ។

វណ្ណៈ	ឥឡូវគាត់នៅណា?

ឌឿៈ	មិនដឹងនៅណាទេ អត់ដែលឃើញផង ។

វណ្ណៈ	បាត់គាត់តាំងពីពេលណាទៅ?

ឌឿៈ	បាត់មិនដឹងទៅណាទេ ។

វណ្ណៈ	បាត់តាំងពីសម័យខ្មែរក្រហម ឬក៏ពីសម័យចប់ហើយឃើញគាត់ទៀត?

ឌឿៈ	សម័យដែលយួនចូលមកឃើញ ដល់ពេលនេះអត់ឃើញទេ ប្រហែលជាបានប្តីទៅនៅឯណាក៏មិនដឹង ។

វណ្ណៈ	ចុះមីងលើកទំនប់ក្រសាំងអត់គ្រាប់ហ្នឹងហើយ មីងទៅធ្វើការនៅទំនប់ស្ពាច់ទៀត?

ឌឿៈ	ទំនប់ស្ពាច់ ។

វណ្ណៈ	ទំនប់ស្ពាច់ហ្នឹងពីណាគ្រប់គ្រងមីងដែរ?

ឌឿៈ	មិនដឹងជាពីណាទេនៅស្ពាច់ហ្នឹង ភ្លេចបាត់ហើយ ។

វណ្ណៈ	ចុះចេញពីទំនប់ស្ពាច់ហ្នឹងមីងទៅណាទៀត?

ឌឿៈ	ទៅកងវ៉ា ។

វណ្ណៈ	ទៅទំនប់កងវ៉ា ទៀត?

ឌៀៈ	មិនមែនទំនប់ទេ មកនៅបាញ់ថ្នាំ គេបញ្ជូនឲ្យមកនៅបាញ់ថ្នាំនៅកងវ៉ា ។

វណ្ណៈ	បាញ់ថ្នាំអីទៅ?

ឌៀៈ	បាញ់ថ្នាំកប្បាស ។

វណ្ណៈ	កងវ៉ានៅស្រុកអី?

ឌៀៈ	មិនដឹងនៅស្រុកអីទេ ដូចជានៅស្វាយយើងនេះ ។

វណ្ណៈ	អញ្ចឹងកាលហ្នឹងកប្បាសហ្នឹងគេធ្វើយកទៅណា?

ឌៀៈ	គេសំពត់ឲ្យយើងស្លៀក ។

វណ្ណៈ	កប្បាសកាលហ្នឹងច្រើន?

ឌៀៈ	ច្រើនណាស់ ច្រើនមែនទែន ភ្នំកងវ៉ាសុទ្ធតែកប្បាស ។

វណ្ណៈ	នៅក្នុងសម័យខ្មែរក្រហមប៉ុន្មានខែ ប៉ុន្មានឆ្នាំគេបើកខោអាវឲ្យយើងម្តង?

ឌៀៈ	មិនដឹងប៉ុន្មាន មិនសូវដឹងទេ យូៗក៏បើកឲ្យ យើងកងចល័តក៏គេបើកឲ្យ ពណ៌សអញ្ចឹងយើងយកទៅជ្រលក់ឲ្យមួយប្រាវទៅ ។

វណ្ណៈ	យើងបើកបានពណ៌សកាលពីសម័យលន់ នល់ អីហ្នឹង ។

ឌៀៈ	អត់ទេ កប្បាសដែលដាំនោះឯង យើងធ្វើជាសំពត់ ។

វណ្ណៈ	ធ្វើត្បាញនៅហ្នឹងទៀត?

ឌៀៈ	ចា៎! គេត្បាញហ្នឹងរោងតម្បាញគេមាន តែមិនដឹងតម្បាញនៅកន្លែងណាទេ ។

វណ្ណៈ	អញ្ចឹងមីងធ្វើនៅកន្លែងកប្បាសហ្នឹងរហូតដល់ចប់៧៩ វៀតណាមចូលមក ឬផ្លាស់ទៅណាទៀត?

ឌៀៈ	អត់បានផ្លាស់ទេ ចប់ក៏មកផ្ទះវិញ ពេលដែលយួនចូលមកក៏រត់ទៅផ្ទះ ។

វណ្ណៈ	កប្បាសកាលមីងធ្វើហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

ឌៀៈ	មិនដឹងប៉ុន្មានទេ ភ្លេចហើយ ។

វណ្ណៈ	មានបុរស មានស្ត្រីដែរ?

ឌៀៈ	ចា៎! មានប្រុស មានស្រី ប្រុសៗគេបាញ់គេលាយថ្នាំ ហើយគេនាំគ្នាបាញ់ យើងក៏បាញ់ដែរ គេឲ្យធុងម្នាក់មួយ ។

វណ្ណៈ	ហើយកាលហ្នឹងបុរសហើយនឹងស្ត្រីមានសិទ្ធស្រលាញ់គ្នាបានទេ?

ឌៀៈ	អត់ហ៊ានទេ ។

វណ្ណៈ អត់ហ៊ានទេ?

ខៀៈ ហ្នឹងហើយ ។

វណ្ណៈ ខ្លាចអី?

ខៀៈ គេវៃចោល ។

វណ្ណៈ គេវៃចោល?

ខៀៈ ចា៎! ចុះបើគេវៃចោលមែន ។

វណ្ណៈ ចុះមានអ្នកខុសសិលធម៌គេយកទៅវៃចោលទេ?

ខៀៈ មាន គេវៃចោលនៅវត្តនេះ ។

វណ្ណៈ ពីណាគេ ឈ្មោះអី?

ខៀៈ អត់ស្គាល់ទេ គ្រាន់តែឃើញគេដឹកអាទេះមក ។

វណ្ណៈ ដឹកមកទាំងអស់ ទាំងស្រីទាំងប្រុសហ្នឹង?

ខៀៈ ចា៎! ទាំងស្រីទាំងប្រុស ។

វណ្ណៈ យកមកដល់គេធ្វើយ៉ាងម៉េច?

ខៀៈ យកមកដល់គេហៅប្រជាជនឲ្យមើល ។

វណ្ណៈ មីងមានបានចូលរួមមើលទេ?

ខៀៈ តែម៉ែខ្ញុំហើយនឹងពុកខ្ញុំទេ ខ្ញុំទៅចល័ត ។

វណ្ណៈ អញ្ចឹងពួកអ៊ំនិយាយ?

ខៀៈ ចា៎! គាត់និយាយថាគេវៃចោល វៃចោលប្រុសមួយស្រីមួយ ហើយស្រីនោះមានទម្ងន់ផង គេវៃចោល ។

វណ្ណៈ យើងអត់ការ យើងអត់ស្នើរអង្គការ?

ខៀៈ ចា៎!

វណ្ណៈ ចុះកាលមីង មីងបានរៀបការកាលជំនាន់ខ្មែរក្រហម?

ខៀៈ ចា៎!

វណ្ណៈ ឆ្នាំណាមីងការ?

ខៀៈ អត់ស្គាល់ទេ ។

វណ្ណៈ អត់ស្គាល់ឆ្នាំទេ?

ខៀៈ ចា៎!

វណ្ណៈ ជិតបែកវៀតណាមចូលប៊ុក៏?

ឌៀ: ជិតចូលមកហើយ ។

វណ្ណៈ ការបានមួយឆ្នាំយួនចូលមែន?

ឌៀ: មិនបានមួយឆ្នាំផង ។

វណ្ណៈ អញ្ចឹង៧៨?

ឌៀ: ចា៎!

វណ្ណៈ កាល៧៨ហ្នឹងការប៉ុន្មានគូរ?

ឌៀ: ការតែ២គូរ ។

វណ្ណៈ តិចណាស់ណេះ?

ឌៀ: គេបើកម្តង៤០ តែនៅស្មើរពេក កាលខ្ញុំនៅអាយុ១៣ឆ្នាំខ្ញុំឃើញគេបើកឡើង៤០គូរ កាលហ្នឹងខ្ញុំឈរមើលគេ បើកម្តង៤០ ម្តង២០ ។

វណ្ណៈ ហើយម៉េចទៀតទៅ ដល់ពេលគូរមីងបានតែ២គូរ?

ឌៀ: ចា៎! ២គូរ ។

វណ្ណៈ ២គូរ កាលហ្នឹងពូមកស្មើរមីងប៊ុក៏យ៉ាងម៉េច?

ឌៀ: ស្មើរនៅសម័យអាពតហ្នឹង ។

វណ្ណៈ ហើយមីងពេញចិត្តគាត់ដែរ?

ឌៀ: ពេញចិត្ត ចុះគេបញ្ជូន ដល់ពេលនេះយើងយកទៅ ដល់ពេលបានប្តីទៅគេចាប់នៅផ្ទះ ។

វណ្ណៈ ចុះដល់ពេលមីងការហើយមានកូនទេកាលហ្នឹង?

ឌៀ: អត់មានទេ ។

វណ្ណៈ ដល់ក្រោយមកទៀតបានមានកូន?

ឌៀ: ចា៎!

វណ្ណៈ មានកូនសម័យហ្នឹងក៏ពិបាកដែរ ព្រោះយើងខ្វះខាតរឿងហូបចុក តែមីងនៅកន្លែងធ្វើកប្បាសហ្នឹងរយៈពេលយូឆ្នាំទេបានវៀតណាមចូល?

ឌៀ: មកនៅប្រហែលជាមួយឆ្នាំហ្នឹង នៅកន្លែងស្រួល បាញ់ថ្នាំហ្នឹងស្រួលជាងលើកទំនប់ នៅយូក្រែលដែរហ្នឹង ។

វណ្ណៈ កន្លែងមីងធ្វើកប្បាសហ្នឹង មានថ្នាក់ធំ អ្នកធំអីគេទៅមើលទេ?

ឌៀ: គេទៅមើល ។

វណ្ណៈ ពីណាគេទៅមើលហ្នឹង?

ឌៀ: អត់ស្គាល់ទេ ភ្លេចហើយ ហើយកាលមេដែលដាំកប្បាសហ្នឹងមិនដឹងពីណាទេភ្លេចហើយ ។

វណ្ណៈ យើងកាលធ្វើទំនប់មួយៗមានមេថ្នាក់លើចុះមកមើលទេ?

ឌៀ: មាន តែកាលខ្ញុំទៅកប្បាសវាប្លែករកនឹកអត់ឃើញទេ ។

វណ្ណៈ អញ្ចឹងកាលលើកទំនប់ កាលលើកទំនប់មានទេ?

ឌៀ: កាលលើកទំនប់មាន មានតារ៉ាល់ ខាងខ្ញុំច្រើនតែ តារ៉ាល់ ទៅមើល ។

វណ្ណៈ តារ៉ាល់?

ឌៀ: អាស៎! តាសំអាត ។

វណ្ណៈ តារ៉ាល់ ទេអី ព្រោះល្បី តារ៉ាល់?

ឌៀ: តារ៉ាល់ នៅទំនប់នេះ ទំនប់រន្ទះបាញ់ ។

វណ្ណៈ មានទំនប់រន្ទះបាញ់ទៀត?

ឌៀ: ចា៎! ទំនប់រន្ទះបាញ់ប៉ុណ្ណាណី ត្រីគេអភិរក្សប៉ុណ្ណាណី ខ្ញុំទៅត្រីឆ្តោប៉ុណ្ណាណី ។

វណ្ណៈ ឥឡូវហ្នឹងមានទៀត?

ឌៀ: មាន ត្រីធំៗ ទំនប់តារ៉ាល់ ។

វណ្ណៈ ចុះមីងទៅធ្វើកប្បាសហ្នឹង ដល់ពេលមីងការហើយ គ្រួសារមីងនៅកន្លែងធ្វើកប្បាសហ្នឹងដែរ?

ឌៀ: ចា៎!

វណ្ណៈ គាត់ខាងផ្នែកយោធា ឬក៏ផ្នែកកម្មករ?

ឌៀ: កម្មករដូចតែគ្នា ។

វណ្ណៈ ធ្វើកប្បាសហ្នឹងពេលយើងដាំយើងបេះមក យើងអត់មានយកទៅខាងណាទៀតទេ?

ឌៀ: មិនដឹងយកទៅខាងណាទេ ស្រាប់តែបាញ់បានទុំហ្នឹងមិនដឹងគេយកទៅណាទេ ។

វណ្ណៈ ប៉ុន្មានរយហិចតាទៅ?

ឌៀ: មិនដឹងប៉ុន្មានរយទេ ច្រើនណាស់មើលមិនដឹងទេ ដូចថាកងខ្ញុំមើលថែហិចតានេះគេឲ្យមើលតែហិចតានេះទេ ។

វណ្ណៈ ហើយមនុស្សរាប់រយរាប់ពាន់?

ឌៀ: ចា៎! មនុស្សច្រើនណាស់ ។

វណ្ណៈ អញ្ចឹងពេលចប់ ពេលមីងធ្វើកប្បាសរហូតដល់យួនចូលអញ្ចឹង មីងរត់ត្រលប់មកផ្ទះវិញទាំងប្តីទាំងប្រពន្ធ?

ខៀ: ចា៎!

វណ្ណៈ អត់រត់ទៅជាយដែនអីទេ?

ខៀ: មកផ្ទះមករកម៉ែរកឪ ។

វណ្ណៈ អត់មានរត់ទៅស្រុកក្រៅរត់អីនឹងគេទេ?

ខៀ: អ៊ំ! អត់ទៅទេ មិនដឹងថាទៅខាងណាទេ រត់មករកតែម៉ែទេ ។

វណ្ណៈ ព្រោះអីនៅជិតៀរខាងហ្នឹងច្រើនតែគេរត់ទៅខាងក្រៅ ទៅស្រុកក្រៅទៅអី?

ខៀ: មិនសូវមានអ្នកណាទៅទេ ច្រើនតែរត់មករកតែម៉ែឪ ពេលយួនចូលមករត់រកតែម៉ែឪ ពួកសម័យអាពតនោះវាកៀរដែរ វាថាទៅខាងជើង តែខ្ញុំអត់បានរត់ទៅខាងជើងទេ ខ្ញុំរត់មកខាងនេះ រត់មកនេះវិញ ។

វណ្ណៈ កៀរទៅជាយដែន?

ខៀ: ចា៎! អ្នកណាដែលអត់ដឹងក៏ទៅ ហើយក៏ទៅតាមវាខ្លាចវាចេះតែទៅ ។

វណ្ណៈ ប៉ុន្តែទៅតាមផ្លូវជួនមានស្លាប់មានអី?

ខៀ: ទៅជាមួយវាបាញ់ចោល យើងទៅមិនរួច វាឲ្យទៅខាងជើងៗតែយើងអត់ទៅទេបកមកនេះវិញ អ្នកទៅក៏ទៅល្ងីនទៅ ខោអាវរែកសំពីងសំពោង ។

វណ្ណៈ ចុះមីងមកដល់ផ្ទះនេះវិញ ហើយមកដល់ភូមិនេះវិញជួបម៉ែឪអញ្ចឹងទៅ?

ខៀ: ជួបនៅស្រុក នៅឯភូមិតាប៉ែន រួចហើយភូមិគេទៅភូមិគេ ហើយភូមិយើងមកភូមិយើងមកជួបម៉ែជួបឪហើយមកភូមិយើងវិញមក ។

វណ្ណៈ ហើយដល់ពេលអញ្ចឹងទៅពូគាត់ចូលធ្វើការ?

ខៀ: ចា៎! គាត់ធ្វើកងពល៦៩ ។

វណ្ណៈ ៦៩?

ខៀ: ចា៎! ខាងរថក្រោះ ។

វណ្ណៈ ខាងរដ្ឋកម្ពុជាយើងហ្នឹង?

ខៀ: ចា៎!

វណ្ណៈ វៃជាមួយខ្មែរក្រហម?

ខៀ: ចា៎! វៃជាមួយខ្មែរក្រហម ។

វណ្ណៈ	វ៉ៃនៅម្តុំណា?

ឌឿៈ	មិនដឹងទេពួកគាត់ គេបញ្ជូនទៅមានទាំងរថក្រោះមានអីគាត់ទៅ។

វណ្ណៈ	កាលដែលពូទៅខាងរថក្រោះទៅអីហ្នឹង មីងមានកូនចៅប៉ុន្មាននាក់ហើយ?

ឌឿៈ	មានហើយ មាន២នាក់។

វណ្ណៈ	មាន២នាក់ហើយ ប៉ុន្តែគាត់ទៅមកៗ?

ឌឿៈ	ចាំ!

វណ្ណៈ	ដល់ក្រោយមកកងពលគាត់គេបញ្ជូនទៅភ្នំពេញឬក៏ម៉េច?

ឌឿៈ	ចាំ! បញ្ជូនទៅភ្នំពេញ។

វណ្ណៈ	ដល់ពេលទៅភ្នំពេញអញ្ចឹងក៏បែកគ្នាទៅ?

ឌឿៈ	ចាំ!

វណ្ណៈ	មីងបែកគាត់ច្រើនឆ្នាំហើយឬក៏ទើបតែបែកទេ?

ឌឿៈ	បែកតាំងពីកូនអាយុ១ឆ្នាំ មីនេះអាយុ១ឆ្នាំ នេះ១៩។

វណ្ណៈ	អំ! យូឆ្នាំហើយ?

ឌឿៈ	ចាំ!

វណ្ណៈ	ពោគេអញ្ចឹង?

ឌឿៈ	ចាំ!

វណ្ណៈ	អញ្ចឹងបែកជាង១០ឆ្នាំហើយ ជិត២០ឆ្នាំហើយ គាត់ដែលមកលេងដល់ផ្ទះទេ។

ឌឿៈ	មក គាត់ឈប់មកកូនបានអាយុ២ឆ្នាំគាត់មក ដល់ហើយគាត់ឈប់មក គាត់អាល័យដាប់រក ស៊ីផង គាត់ឈឺផង គាត់ឲ្យតែខ្ញុំទៅយកលុយ តែខ្ញុំទៅយកម្តង២ដងទៅ ដល់ពេលនេះខ្ញុំឈប់ ទៅ។

វណ្ណៈ	ឥឡូវគាត់អាត្រែត ឬក៏គាត់នៅធ្វើការ?

ឌឿៈ	គាត់ឈប់ហើយ គាត់ឈប់ធ្វើការហើយ គាត់រកស៊ីម្តង ពូកូនថារកស៊ីលក់ទឹកកកព្រិលលក់អី ហើយបើកឡានលក់ទឹកកកព្រិល។

វណ្ណៈ	គាត់មានកូនចៅច្រើនទៀតដែរ ប្រពន្ធក្រោយហ្នឹង?

ឌឿៈ	ចាំ! មាន២នាក់។

វណ្ណៈ	ចុះមីង មកដល់សព្វថ្ងៃនេះមីងធ្វើការប្រកបមុខរបរអីខ្លះទៅ?

ឌៀៈ មុនខ្ញុំជួញត្រី លក់ត្រីលក់អី តែសព្វថ្ងៃខ្ញុំអត់បានលក់ទេខ្ញុំកើតទឹកនោមផ្អែម ដល់ពេលអញ្ចឹង ខ្ញុំអត់មានបានរកអីផង ស្រវាំងភ្នែកផងអត់មានបានរកអីទេ ។

វណ្ណៈ ចុះអ្នកស្រុកនេះមួយចំនួនគេទៅរកស៊ីស្រុកថៃដែរឬក៏យ៉ាងម៉េច?

ឌៀៈ ទៅ ទៅថៃឡើងចង់ស្វាត់ ទៅច្រើនណាស់ បានប្ដីរួចទៅៗ គេទៅរកស៊ីគេចង់មានចង់បាន ។

វណ្ណៈ បានប្ដីទៅវិញ?

ឌៀៈ ការរួចដឹងតែទៅថៃហើយ ។

វណ្ណៈ ម៉េចអញ្ចឹង?

ឌៀៈ ទៅទាំងប្ដីទាំងប្រពន្ធ គេរកបាន ។

វណ្ណៈ អត់ទាន់ការអត់ទាន់រកស៊ីអីទេ?

ឌៀៈ ទៅ ពួកក្មេងៗទៅ ចំណាស់ក៏ទៅ ទុកកូនឲ្យម្ដាយហើយក៏ទៅ ។

វណ្ណៈ អញ្ចឹងកូនមីងអត់មានទៅនឹងគេទេ?

ឌៀៈ អត់ទេ នៅធ្វើតែស្រែខ្ពិលឲ្យទៅណាស់ ។

វណ្ណៈ ទៅស្រុកគេក៏យើងវាពិបាកដែរ យើងមើលមិនឃើញដែរ ហើយវាអាញ៉ៅអាញ៉ៅដែរ ហើយ ថៃហ្នឹងវាមិនសូវចូលចិត្តយើងដែរ ខ្លាចតែធ្វើបាបធ្វើអីដែរហ្នឹង ។

ឌៀៈ អញ្ចឹងមីងមានអីនិយាយទេ ខ្ញុំដូចជាអស់អីសួរមីងហើយ?

វណ្ណៈ ខ្ញុំអត់មានទេ ។

ឌៀៈ អញ្ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

វណ្ណៈ ចា៎!

«ចប់»